ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.........................................................

# មតិបិទ

## របស់លោកជំទាវ ជា សិរី អគ្គនាយកបច្ចេកទេស

## ក្នុងឱកាសសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១ របស់ធនាគារជាតិនៃកម្ពុជា ស្តីពី "ការពង្រីកការផ្តល់ហិរញ្ញប្បទាន និងការរក្សាស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា"

**ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ នៅសណ្ឋាគារ Raffles Hotel Le Royal ភ្នំពេញ**

*************

សូមគោរព

- **លោក ជំទាវទេសាភិបាលរង និងគណៈអធិបតី ជាទីគោរព**
- **ឯកឧត្តម លោកជំទាវ លោកជំនាញការ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

សន្និសីទរបស់យើងបានឈានមកដល់ទីបញ្ចប់ហើយ ។ ជារួម ខ្ញុំសូមវាយតម្លៃខ្ពស់ថា សន្និសីទនេះបានប្រព្រឹត្តទៅយ៉ាងរលូន និងប្រកបដោយជោគជ័យ ។ តាងនាមឲ្យធនាគារជាតិនៃកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមដ៏សកម្មរបស់ ឯកឧត្តម លោកជំទាវ លោកជំនាញការ លោក លោកស្រី ទាំងអស់ ក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍លើប្រធានបទរបស់យើងនៅពេលនេះ ។

**ឯកឧត្តម លោកជំទាវ លោកជំនាញការ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

សន្និសីទនៅថ្ងៃនេះ បានផ្តោតលើ ៣ ប្រធានបទសំខាន់ៗ គឺ បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា លំហូរមូលធន និងការអភិវឌ្ឍតំបន់ជនបទនៅកម្ពុជានិងតម្រូវការឥណទាន។

ដូចដែល ឯកឧត្តម ទេសាភិបាល បានមានប្រសាសន៍នាព្រឹកនេះ ហើយកិច្ចពិភាក្សារបស់យើងក៏បានបង្ហាញដែរ បរិយាប័ន្នហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សមភាព និងបរិយាប័ន្ន ។ ការពង្រីកសេវាហិរញ្ញវត្ថុឲ្យកាន់តែទូលាយ គឺជាការផ្តល់ឱកាសដល់ក្រុមគ្រួសារ និងសហគ្រាស ក្នុងការទទួលបានធនធានហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍសកម្មភាពអាជីវកម្ម ។ នៅក្នុងការពិភាក្សា យើងក៏បានលើកឡើងពី



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ទំនាក់ទំនងរវាងបរិយាប័ន្នហិរញ្ញវត្ថុ និងការកាត់បន្ថយភាពក្រីក្រ កំណើនសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ។ ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនឹងរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងសង្គម បង្កើនសកម្មភាពសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។

ទន្ទឹមនេះ ការជំរុញពង្រីកការផ្តល់សេវាហិរញ្ញវត្ថុក៏ត្រូវគិតផងដែរពីហានិភ័យ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ។ បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលមក លំហូរមូលធនបានប្រែប្រួលគួរឲ្យកត់សម្គាល់ និងបានក្លាយជាបញ្ហាមួយដ៏សំខាន់សម្រាប់អ្នករៀបចំគោលនយោបាយ ។ ការកើនឡើងនៃលំហូរមូលធនមានសារៈសំខាន់ក្នុងការពង្រីកនិងបង្កើនហិរញ្ញប្បទាន ក៏ប៉ុន្តែការកើនឡើងនេះក៏អាចបង្កជាហានិភ័យធ្វើឲ្យមានអស្ថិរភាពលើកំណើនសេដ្ឋកិច្ច អត្រាប្តូរប្រាក់ និងវិស័យហិរញ្ញវត្ថុទាំងមូល ហើយលំហូរចេញនៃមូលធនក៏អាចបណ្តាលឲ្យមានហានិភ័យលើស្ថិរភាពហិរញ្ញវត្ថុផងដែរ ។ ដូចនេះ ការពង្រីកការផ្តល់សេវាហិរញ្ញវត្ថុត្រូវតែធ្វើឡើងក្នុងក្របខណ្ឌប្រុងប្រយ័ត្ន ដើម្បីជៀសវាងហានិភ័យដែលអាចកើតឡើងជាយថាហេតុ ប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ ។ ធនាគារជាតិនៃកម្ពុជា បានធ្វើការសិក្សាស្រាវជ្រាវពីឥទ្ធិពលនៃការចាក់បញ្ចូលទុនក្នុងទីផ្សាររបស់ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍មកលើសេដ្ឋកិច្ចកម្ពុជាផងដែរ ។ យោងតាមលទ្ធផលនៃការសិក្សា សេដ្ឋកិច្ចកម្ពុជាមិនបានទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ពីការចាក់បញ្ចូលទុននោះឡើយ ដោយសារលំហូរមូលធនភាគច្រើនគឺមានទម្រង់ជាលំហូរវិនិយោគផ្ទាល់បរទេស ។

ម្យ៉ាងវិញទៀត វិស័យកសិកម្មនៅតែបន្តជាសសរស្តម្ភក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងជំរុញការនាំចេញអង្ករឲ្យបាន ១លានតោននៅឆ្នាំ២០១៥ ។ ដូចនេះ ការពង្រីកការផ្តល់ហិរញ្ញប្បទាន គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយអភិវឌ្ឍវិស័យកសិកម្មក៏ដូចជាសេដ្ឋកិច្ចទាំងមូលឲ្យមានការរីកចម្រើន ។ វិស័យមីក្រូហិរញ្ញវត្ថុបានរួមចំណែកកាន់តែសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់វិស័យកសិកម្ម ។

**ឯកឧត្តម លោកជំទាវ លោកជំនាញការ លោក លោកស្រីទាំងអស់ ជាទីមេត្រី!**

ការស្រាវជ្រាវ គឺពិតជាមានសារៈសំខាន់ណាស់ ក្នុងការទទួលបាននូវព័ត៌មាន លទ្ធផលនៃការវិភាគ និងផ្តល់ជាដំណោះស្រាយលើបញ្ហានានា ។ ដូចនេះ ដើម្បីលើកកម្ពស់ការស្រាវជ្រាវ ខ្ញុំសូមលើកទឹកចិត្តដល់អ្នកស្រាវជ្រាវ និងសេដ្ឋវិទូនានា បង្កើនការស្រាវជ្រាវទៅលើប្រធានបទពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ សំដៅរួមចំណែក



ឈ

ផ្តល់ធាតុចូលដល់ការបង្កើតវិធានការនិងគោលនយោបាយនានា គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព ។

សន្និសីទនេះគឺជាសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី១ របស់ធនាគារជាតិនៃកម្ពុជា ហើយធនាគារជាតិនៃកម្ពុជានឹងរៀបចំជាបន្តបន្ទាប់ទៀត ដើម្បីបង្កើតជាវេទិកាពិភាក្សាលើប្រធានបទស្តីពី ម៉ាក្រូសេដ្ឋកិច្ចនិងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ ខ្ញុំសង្ឃឹមថានៅឆ្នាំក្រោយ សន្និសីទនេះនឹងមានអ្នកស្រាវជ្រាវចូលរួមកាន់តែច្រើន ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីម្តងទៀតដល់ការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោកជំនាញការ លោក លោកស្រីទាំងអស់ ។ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោកជំនាញការ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ កម្លាំងមាំមួន ប្រាជ្ញាវាងវៃ និងមានជ័យជំនះគ្រប់ភារកិច្ច ។

**សូមអរគុណ!**